**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៤៥១
ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៣
**សាលដីកា**
លេខ:២១៤
ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............ ជាប្រធាន
២-លោក .............. ជាចៅក្រម
៣-លោក ............... ជាចៅក្រមរបាយការណ៍
៤-លោក ................. ជាចៅក្រម
៥-លោក ................. ជាចៅក្រម

**ក្រឡាបញ្ជី**

-កញ្ញា ..................

**តំណាងមហាអយ្យការ**

-ឯកឧត្តម ............... ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ១២៥(ឈ) ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤៨១ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង:

ដើមចោទឈ្មោះ Xi Xiang Rong (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥១ឆ្នាំ ជនជាតិចិន មុខរបរអគ្គនាយកក្រុមហ៊ុន ហ៊ុយ សេង ទីលំនៅសព្វថ្ងៃស្នាក់នៅសណ្ឋាគារពន្លឺព្រះអាទិត្យ ផ្លូវព្រះស៊ីសុវត្ថ សង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មានមេធាវីលោក................ និងលោក ................ ។

ចុងចម្លើយឈ្មោះ WEBING QING (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៦២ឆ្នាំជនជាតិចិន មុខរបរប្រធានក្រុមហ៊ុន ហ៊ុយ សេង ទីលំនៅសព្វថ្ងៃស្នាក់នៅទីស្នាក់ការក្រុមហ៊ុនក្នុងផ្សារអូរឫស្សី ។

តំណាងដោយលោកអាន ដោពីង ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិចិន ស្នាក់នៅទីស្នាក់ការក្រុមហ៊ុនហ៊ុយសេង ក្នុងផ្សារអូរឫស្សី ។

មានលោក ................ ជាមេធាវី ។

ចុងចម្លើយឈ្មោះWU PICHI (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៥ឆ្នាំ ជនជាតិចិន មុខរបរអគ្គនាយកក្រុមហ៊ុន GCD ។

តំណាងដោយលោកសួរ សារិទ្ធ ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៤៦ ផ្លូវលេខ៣៦៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

មានមេធាវីលោក ................ ។

កម្មវត្ថុបណ្តឹង ប្តឹងសុំចេញដីកាសម្រេចតាមពាក្យសុំផ្អាកការអនុវត្តជាបណ្តោះអាសន្ននូវដីកាសំរេចតាមលទ្ធផលសេះជាលេខ០១(ជ) ចុះថ្ងៃទី៨-៤-២០០៣ របស់តុលាការក្រុងភ្នំពេញ និងសុំហាមឃាត់ការលក់ដូរ,ជួលតូប ស្តង់និងអាគារ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣៤៣ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះសួរ សារិទ្ធ តំណាងឲ្យឈ្មោះ Wu Pi Chi ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១២៥(ឈ) ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកា ទាំងមូល ។

បានឃើញបណ្តឹងសាទុក្ខលេខ៣២៧ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះអាន តោភីង តំណាងឱ្យក្រុមហ៊ុនហ៊ុយសេង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១២៥(ឈ) ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៥១ប្រ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៩-៥-២០០៣ របស់លោកមេធាវី................ និងលោកមេធាវី................ តំណាងឱ្យឈ្មោះXIE XIANG RONG ប្តឹងសុំឱ្យតុលាការចេញដីកាសម្រេចតាមពាក្យសុំផ្អាកការអនុវត្តជាបណ្តោះអាសន្ននូវដីកាសម្រេចតាមលទ្ធផលសេះជាលេខ០១(ជ) ចុះថ្ងៃទី០៨-៤-២០០៣ របស់តុលាការក្រុងភ្នំពេញ និងហាមឃាត់ការលក់ដូរ ជួលតូប ស្តង់ និងអាគារ ដែលមាននៅក្នុងដីកានោះ ដោយសំអាងហេតុថា ដីកាសម្រេចតាមលទ្ធផលសេះជាលេខ០១(ជ) ចុះថ្ងៃទី០៨-៤-២០០៣ ចេញដោយតុលាការក្រុងភ្នំពេញ តាមការអះអាងរបស់លោកWEI BING QING ជាប្រធានក្រុមហ៊ុនហ៊ុយសេង បានឃុបឃិតជាមួយជនទុច្ចរិតមួយចំនួនក្នុងក្រុមហ៊ុន និងជាមួយក្រុមហ៊ុនដែលជាដៃគូបាននាំគ្នាធ្វើការសម្រេចដោយអត្តនោម័ត គ្មានការឯកភាពពីម្ចាស់ភាគហ៊ុនដទៃទៀត ដែលផ្ទុយពីច្បាប់និងលក្ខន្តិកៈរបស់ក្រុមហ៊ុនក្នុងបំណងបំបាត់ និងរំលោភយកភាគហ៊ុនរបស់កូនក្តីខ្លួន ។ ជាក់ស្តែងពួកគេបានធ្វើការបែងចែកស្តង់ តូប និងអាគារតាមតែអំពើចិត្តដូចមាននៅក្នុងដីកាសម្រេចតាមលទ្ធផលសេះជាខាងលើនេះ ។ ក្នុងរឿងនេះសូមលោកប្រធានមេត្តាមានវិធានការជាបន្ទាន់ដើម្បីទប់ស្កាត់នូវរាល់ទង្វើដោយខុសច្បាប់ទាំងឡាយ ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ០៤(ជ) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី១៥-០១-២០០២ របស់ឈ្មោះWEI BING QING ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-ទទួលលិខិតផ្ទេរសិទ្ធិ និងតំណាងសិទ្ធិចុះថ្ងៃទី០៧-០២-២០០២ របស់ឈ្មោះWEI BING QING ជាប្រធានក្រុមហ៊ុនហ៊ុយសេង ផ្ទេរសិទ្ធិឱ្យមកលោកមេធាវីសោម ច័ន្ទឌីណា ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-ទទួលលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២០-១២-២០០១ របស់ឈ្មោះ Wu Pi Chi ផ្ទេរសិទ្ធឱ្យមកឈ្មោះសួរ សារិទ្ធ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-លុបដីកាសម្រេចតាមពាក្យសុំលេខ០៧(ជ) ចុះថ្ងៃទី២៦-១២-២០០១ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៥-បង្កើតគណៈកម្មការពិសេសមួយមានគូភាគី តុលាការក្រុងភ្នំពេញ មន្ទីរហិរញ្ញវត្ថុ រាជធានីភ្នំពេញ លក់ ឬជួលនូវអាគារការិយាល័យជាន់ទី៣ ជាន់ទី៤ និងជាន់ទី៥ ចំណតរថយន្តជាន់ទី២ និងជាន់ដំបូលហាងលក់ទំនិញចំនួន

៣៨ហាង និង ស្តង់ចំនួន៣៦ នៅក្នុងផ្សារ អូរឫស្សី ទៅតាមតម្លៃជាក់ស្តែង ហើយប្រាក់ដែលបានពីការលក់រក្សាទុកក្នុងគណនីរបស់ តុលាការក្រុងភ្នំពេញ រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី ។

៦-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន២.០០០រៀល ពីដើមបណ្តឹងទាស់ ដែលបានបង់ទុកមុនជាស្រេច ។

៧- ដីកាសម្រេចនេះមានអានុភាពយកទៅអនុវត្តបានភ្លាមៗ ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៨-ដីកានេះសម្រេចចំពោះមុខតំណាងដើមបណ្តឹងទាស់និងតំណាងចុងបណ្តឹងទាស់ បើភាគីណាមិនសុខចិត្តនឹងដីកាសម្រេចនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញដីកាសម្រេចតាមលទ្ធផលសះជាលេខ០១(ជ) ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-កត់សម្គាល់ថា គូភាគីបានព្រមព្រៀងគ្នាដូចខាងលើ

២-ទទួលស្គាល់ការព្រមព្រៀងគ្នានេះ ទុកជាបានការតាមច្បាប់តទៅ

៣-ដីកាសម្រេចនេះ មានអានុភាពយកទៅអនុវត្តបាន ដូចសាលក្រមស្ថាពរ ។

បានឃើញដីកាសម្រេចតាមពាក្យសុំលេខ ១១(ញ) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី២៩-៥-២០០៣ របស់មេធាវីតំណាង............... និងលោក............... ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ផ្អាក់ជាបណ្តោះអាសន្នការអនុវត្តដីកាសម្រេចតាមលទ្ធផលសះជាលេខ០១(ជ) ចុះថ្ងៃទី០៨-៤-២០០៣ របស់តុលាការក្រុងភ្នំពេញ ។

៣-ហាមលក់ ជួលតូប-ស្តង់ និងអាគារ ដែលមានក្នុងដីកាសម្រេចតាមលទ្ធផលសះជាលេខ០១(ជ) ចុះថ្ងៃទី០៨-៤-២០០៣ របស់តុលាការក្រុងភ្នំពេញ ទុកជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់រឿ ងអង្គសេចក្តី ។

៤-បង្គាប់ឱ្យលោកមេធាវីតំណាង............... និងលោក............... បង់ប្រាក់ប្រដាប់ក្តីចំនួន២០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល ប្រាក់កាត់យកពីប្រាក់ដើមចោទបានបង់ទុករួចជាស្រេច ។

៥-ភាគីណាមួយមិនសុខចិត្តនឹងដីកាសម្រេចនេះ មានសិទ្ធិប្តឹងទាស់ក្នុងរយៈពេល៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹងពីដីកាសម្រេចនេះទៅ ។

បានឃើញពាក្យបណ្តឹងបដិសេធ ចុះថ្ងៃទី២៣ ខែមិថុនាឆ្នាំ២០០៣ របស់ឈ្មោះអាន ដៅពីង ប្តឹងមិនសុខចិត្តនឹងដីកាសម្រេចតាមពាក្យសុំលេខ១១(ញ) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៣ របស់ តុលាការក្រុងភ្នំពេញត្រង់ចំណុចដីកាសម្រេចទាំងមូល ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ០៥(ឌ) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២៣-០៦-២០០៣ របស់ឈ្មោះអាន ដៅពីង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប ។

២-ទទួលលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី១០-១២-២០០១ របស់ឈ្មោះ Wu PiChi ឱ្យមកឈ្មោះសួរ សារិទ្ធិ ជាតំណាងទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-ទទួលលិខិតប្រគល់សិទ្ធិរបស់ Wei Bing Qing ឱ្យមកឈ្មោះអាន ដោពីង ទុកជាត្រឹមត្រូវច្បាប់ ។

៤-ទទួលលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី០២-០៣-២០០៣ របស់ឈ្មោះសៀសៀងរ៉ុង ឱ្យមកមេធាវី................ និង ................ តំណាងទុកជាត្រឹមត្រូវតាមច្បាប់ ។

៥-បដិសេធដីកាសម្រេចតាមពាក្យសុំលេខ១១(ញ) ចុះថ្ងៃទី១០-០៦-២០០៣ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ចាប់ពីថ្ងៃនេះតទៅ ។

៦-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន២០០៛ ពីដើមបណ្ដឹងទាស់ អាន ដៅពីង ដែលបានបង់ទុកមុនជាស្រេច ។

៧-ដីកាសម្រេចនេះ មានអនុភាពយកទៅអនុវត្តបានភ្លាមៗ ទោះបីមានបណ្ដឹងឧទ្ធរណ៍ក៏ដោយ ។

៨-ដីកានេះសម្រេចចំពោះមុខគូភាគី បើភាគីណាមិនសុខចិត្ត និងដីកាសម្រេចនេះមានសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ១៩(ឧ)ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៣ របស់លោកមេធាវី................ ប្ដឹងមិនសុខចិត្តនឹងដីកាសម្រេចកិច្ចការប្រញាប់លេខ០៥(ឌ)ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចដីកាសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១២៥(ឈ)ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០១-៨-២០០៣ របស់លោកមេធាវី................ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធដីកាសម្រេចកិច្ចការប្រញាប់លេខ០៥(ឌ) ចុះថ្ងៃទី១៥-៧-២០០៣ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣-បដិសេធដីកាសម្រេចតាមពាក្យសុំលេខ១១(ញ) ចុះថ្ងៃទី១០-៦-២០០៣ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៤-ផ្អាក់ការអនុវត្ត ដីកាសម្រេចតាមលទ្ធផលសះជាលេខ០១(ជ) ចុះថ្ងៃទី០៨-៤-២០០៣ របស់តុលាការក្រុងភ្នំពេញ ជាបណ្ដោះអាសន្នសិន ។

៥-បង្កើតគណៈកម្មការពិសេសមួយដឹកនាំដោយតុលាការក្រុងភ្នំពេញ ដែលមានសមាសភាពតុលាការក្រុងភ្នំពេញ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ តំណាងសាលាក្រុងភ្នំពេញ និងគូភាគីដើម្បីធ្វើការលក់ដូរជួលតូបស្តង់ និងអគារផ្សេងៗក្នុងផ្សារអូរឫស្សីដែលនៅសល់ត្រឹមថ្ងៃទី២៦-៨-២០០៣ ហើយប្រាក់ដែលបានពីការលក់ដូរ,ជួលនេះ ត្រូវរក្សាទុកក្នុងគណនីរបស់តុលាការក្រុងភ្នំពេញជាបណ្ដោះអាសន្នសិន ទំរាំតុលាការសម្រេចរឿងអង្គសេចក្ដីចប់ជាស្ថាពរ ។

៦-អនុញ្ញាតឱ្យគណៈកម្មការពិសេសដកយកប្រាក់ដែលបានដូចក្នុងចំណុចទី៥ ខាងលើមួយចំនួនសម្រាប់ចំណាយទៅលើការចាំបាច់មួយចំនួន គឺថ្លៃទឹកថ្លៃភ្លើងប្រាក់ខែបុគ្គលិក កម្មករប្រាក់សម្រាប់ធ្វើការអភិវឌ្ឍន៍បន្តនូវគម្រោងកិច្ចសន្យាជាមួយរដ្ឋប្រាក់ពន្ធត្រូវបង់ជូនរដ្ឋនិងប្រាក់១០% ដែលជាចំណែករបស់សាលាក្រុងភ្នំពេញ ។

៧-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥០០០៛

៨-សាលដីកានេះមានអនុភាពអនុវត្តភ្លាមៗ ទោះជាមានបណ្ដឹងសាទុក្ខក៏ដោយ។

៩-សាលដីកានេះដំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៦-៨-២០០៣ ចំពោះមុខមេធាវីតំណាងឲ្យឈ្មោះស៊ា ស៊ាងរ៉ុង (Xei Xiang Rong) មេធាវីតំណាងឲ្យឈ្មោះ Wu Pi Chi និង Hoan Jen Ta កំបាំងមុខឈ្មោះហ៊ុយ ពីងឈីង ហៅ Wei Bing Qing និងប្រកាសកាសជាសាធារណៈនៅថ្ងៃទី២៧-៨-២០០៣ ចំពោះមុខមេធាវីតំណាងឱ្យឈ្មោះស៊ា សារ៉ុង កំបាំងមុខមេធាវីតំណាង ឱ្យឈ្មោះ Wu Pi Chi និង Hoan Jen Ta និងឈ្មោះហ៊ុយ ពីងឈើង បើកផ្លូវប្តឹងសាទុក្ខតាម កំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣៤៣ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះសួរ សារិទ្ធ តំណាងឲ្យឈ្មោះ Wu Pi Chi ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១២៥ (ឈ) ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាងមូល ។

បានឃើញបណ្តឹងសាទុក្ខលេខ៣២៧ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះអាន តៅភីង តំណាងឱ្យក្រុមហ៊ុនហ៊ុយសេង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១២៥(ឈ) ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តី សម្រេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ឈ្មោះសួរ សារិទ្ធ ។

បានឃើញសារណាតប ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៤ របស់លោក................ ជាមេធាវីការពារឱ្យដើមចោទ ។

បានឃើញសារណា ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះអាន ដោពីង ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា សាលដីការដ្ឋប្បវេណីលេខ១២៥(ឈ) ចុះថ្ងៃទី២៧-៨-២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានបានសម្រេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទម្រង់ និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្តាប់ក្រឡាបញ្ជីអានសារណារបស់លោកសួរ សារិទ្ធ តំណាងឱ្យចុងចម្លើយ និងជាម្ចាស់បណ្តឹងសាទុក្ខ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកប៊ុន ហុន ជាមេធាវីការពារឱ្យលោកអាន ដោពីង ជាចុងចម្លើយ និងជាម្ចាស់បណ្តឹងសាទុក្ខ បានលើកឡើងថាៈ កូនក្តីខ្លួនបានសុំដកបណ្តឹងសាទុក្ខ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក................ ជាមេធាវីការពារឱ្យលោក Wu Pi Chi មានលោកសួរ សារិទ្ធ ជាតំណាង បានលើកឡើងថាៈ ក្នុងរឿងនេះ ខ្លួនសុំចែកចេញជាបី ចំណែក :

I-ចេតនាទុច្ចរិតរបស់អ្នកស្រីស៊ា ស៊ារ៉ុង មានជាច្រើនករណី :

១-ចាត់ចែងការងារចំណូលចំណាយដោយគ្មានគណនេយ្យរួមរវាងក្រុមហ៊ុនទាំងពីរ

២-បើកលេខគណនីថ្មី ក្បត់ក្រុមហ៊ុនដើម្បីឱ្យអាជីវករផ្សារបង់ប្រាក់ថ្លៃតូបចូល ។

៣-បើកប្រាក់ពីធនាគារដោយគ្មានហត្ថលេខារួមរវាងគូភាគី(ផ្ទុយពីកិច្ចសន្យា) ។

៤-ចំណាយបំពានអស់១.៥០០.០០០ដុល្លាអាមេរិក ថាយកទៅជួយដល់គណបក្សប្រឆាំង ។

៥-បំពានលើដីកាសម្រេចកិច្ចការប្រញាប់របស់តុលាការ ។

៦-យកអំណាចអភិបាលក្រុងមកគាបសង្កត់តុលាការធ្វើឱ្យការអនុវត្តដីកាសម្រេចរបស់តុលាការមិនបានសម្រេច

៧-អ្នកស្រីស៊ា ស៊ាងរ៉ុង មានភាគហ៊ុននៅក្នុងការសាងសង់ផ្សារអូរឫស្សីតែចំនួន២៩% ស្មើ៦២០.០០០ដុល្លា ប៉ុន្តែអ្នកស្រីបានទទួលស្គាល់ថា អ្នកស្រីបានដកយកសាច់ប្រាក់អស់ចំនួនជាង១៩.០០០.០០០ដុល្លា ដោយមិនទាន់ធ្វើការទូទាត់ឱ្យសមាជិកភាគហ៊ុនទេ ។

**II-អំពីដីកាសះជាៈ**

ដីកាសះជានេះ គ្មានប៉ះពាល់ដល់ផលប្រយោជន៍អ្នកស្រីស៊ា ស៊ាងរ៉ុងទេ ព្រោះថាការបែងចែក គឺបែងចែកចំណែកដែលនៅសេសសល់បន្តិចបន្តួចពីក្រុមហ៊ុនហ៊ុយសេង ដែលបានលក់រួច ហើយដែលឈ្មោះស៊ា ស៊ាងរ៉ុង យកទៅតែម្នាក់ឯង ដោយពុំអនុវត្តតាមដីការបស់តុលាការក្រុង ។

**III-ដីកាសម្រេចរបស់តុលាការក្រុងភ្នំពេញៈ**

បណ្តឹងសុំហាមឃាត់ការលក់ដូរជួលបញ្ចាំ ផ្ទេរសិទ្ធិ ឬធ្វើអំណោយ អាគារការិយាល័យ ជាន់ទី៣-៤-៥ ចំណាតរថយន្តជាន់ទី២ ជាន់តំបូល ហាងលក់ទំនិញចំនួន៣៨ហាង និងស្តង់៣៦ នៅក្នុងផ្សារអូរឫស្សី បានចូលជាស្ថាពរតាមដីកាសម្រេចកិច្ចការប្រញាប់លេខ០៤(ជ) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ រួចហើយ ប៉ុន្តែអ្នកស្រីពុំបានអនុវត្តទេ អ្នកស្រីរំលោភលក់អាគារ លក់ហាង ទំនិញ តូប ទាល់តែអស់យកប្រាក់តែម្នាក់ឯង រួចហើយបានមកប្តឹងហាមឃាត់ភាគីខ្លួនមិនឱ្យលក់មិនឱ្យជួលអាគារ តូប ហាងទំនិញតាមក្រោយ ។ ដូច្នេះតុលាការពុំមានសមត្ថកិច្ចសម្រេចហាមឃាត់ លើកម្មវត្ថុដដែល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក................ ជាមេធាវីការពារឱ្យដើមចោទ និងជាចុងបណ្តឹងសាទុក្ខបានធ្វើសេចក្តីសន្និដ្ឋានថា : ក្នុងរឿងនេះ ជាវិវាទពាណិជ្ជកម្ម មិនមែនជាវិវាទព្រហ្មទណ្ឌទេ ។ អ្វីដែលលោក...............លើកឡើងសុទ្ធតែជារឿងអង្គសេចក្តី ។ ត្រង់ថា កូនក្តីខ្លួនមិនអនុវត្ត និងនៅតែបំពាននោះ មិនមែនថាកូនក្តីខ្លួនមិនអនុវត្តទេ ។ ហើយអំពី ដីកាសម្រេចកិច្ចការប្រញាប់លេខ០៤(ជ) ចុះថ្ងៃទី២៥-០២-២០០២ ដែលលោកមេធាវីលើកឡើងថាចូលជាស្ថាពរហើយ តុលាការគប្បីចេញវិធានការបណ្តោះអាសន្នអ្វីទៀតទេនោះ គឺមិនត្រឹមត្រូវទេ គឺដើម្បីផលប្រយោជន៍របស់ខ្លួនតែប៉ុណ្ណោះ ក្រោយមកទៀតលោកសុក សេដ្ឋីមុនី បានចេញដីកាសម្រេចលទ្ធផលសះជាលេខ ០១ (ជ) ចុះថ្ងៃទី០៨-៤-២០០៣ ដូច្នេះដីកាសម្រេចកិច្ចការប្រញាប់ត្រូវ អស់សុពលភាពសម្រាប់អនុវត្ត ដោយជំលោះនូវដីកាសម្រេចតាមលទ្ធផលសះជាវិញ ។ ហើយចំពោះ ដីកាសម្រេចកិច្ចការប្រញាប់លេខ០៤(ជ) ចុះថ្ងៃទី២៥-០២-២០០២ នោះពុំត្រឹមត្រូវទេ ដោយដីកា សម្រេចកិច្ចការប្រញាប់នេះ ចេញនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ទេមិនអនុវត្តដោយខ្លួនឯងរហូតដល់ថ្ងៃទី២៥-០២-២០០៣ ទើបចេញសេចក្តីសម្រេចលេខ ៦០៩ ចុះថ្ងៃទី២៥-០២-២០០៣ ឱ្យបង្កើតគណៈកម្មការពិសេសមួយ ។ ហើយនៅថ្ងៃដដែល ក៏មានដីកាបង្គាប់ឱ្យនាំកូនក្តីខ្លួន ហើយ ថ្ងៃបន្ទាប់មកទៀតបានចាប់លោកហ៊ុយ ពីងឈើង ដាក់គុកព្រៃស ហើយដកសិខិតឆ្លងដែននិងបង្ខំឱ្យគាត់ធ្វើដីកាសះជា ដែលគាត់មានអាយុជាង ៧០ឆ្នាំហើយ ។

IV-អំពីដីកាសះជាលេខ០១(ជ) ចុះថ្ងៃទី០៨-៤-២០០៣ ក្នុងនោះកូនក្តីខ្លួនក៏មានភាគហ៊ុនដែរ ដោយពេលនោះមានបញ្ហាទំនាស់ផ្ទៃក្នុងរួចហើយ ។ ហើយឆ្លៀតឱកាសដោយកូនក្តីខ្លួនភ័យខ្លាច បានចេញទៅក្រៅប្រទេស បានឆ្លៀតយកស្ថានភាពនេះ ធ្វើការគាបសង្កត់ឱ្យលោកហ៊ុយពីងឈើង ទើបតែដោះលែងពីឃុំ និងមានជំងឺឱ្យធ្វើដីកាសះជានេះឡើង ដូចមានក្នុងលិខិតរបស់លោកអាន ដោពីង ដូចនេះកូនក្តីខ្លួនប្តឹងជំទាស់នឹងដីកាសជានេះ ។ ហើយដីកាសជាអាចអនុវត្តបានលុះត្រាតែគ្មានបណ្តឹង ជាគោលការណ៍គេអាចចេញដីកាសជា បានចំពោះតែរឿងតូចៗទេ តែរឿង នេះធំបំផុត ។ ចំពោះការពាក់ព័ន្ធនេះ គ្មានលិខិតឫឯកសារណាមួយដែលបញ្ជាក់ថា កូនក្តីខ្លួនដកអស់១៩លានដុល្លាទេ

ហើយការសម្រេចរបស់សាលាឧទ្ធរណ៍គឺមានលក្ខណៈជាបណ្តោះអាសន្នទេ តែកូនក្តីលោកបែរជារំលោភយកទ្រព្យសម្បត្តិដែលនៅសល់ យកទៅចាយទៅវិញ ឯបញ្ហាមួយទៀត ដែលថាមានសំពាធពីសាលាក្រុង គឺមិនត្រឹមត្រូវទេ គឺកូនក្តីខ្លួនធ្វើអ្វីៗដើម្បីមុខមាត់សាលាក្រុងទេ ខ្លួនសំណូមពរសុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក............... ជាមេធាវីការពារឱ្យដើមចោទ និងជាចុងបណ្តឹងសាទុក្ខ បានលើកឡើងថាៈ អ្វីដែលលោកមេធាវីចុងចម្លើយលើកឡើង សុទ្ធតែជា រឿងអង្គសេចក្តី ហើយលោកមេធាវី...............លើកឡើងរួចមកហើយ ដូចនេះខ្លួនសុំច្បិចយកតែចំណុចខ្លះៗយកមកនិយាយៈ

-សិទ្ធិប្តឹងទាស់ : ភាគីខ្លួនមានសិទ្ធិប្តឹងទាស់ ព្រោះដីកាសះជានេះ គ្រាន់តែ ជាកិច្ចសន្យារបស់គូភាគី ដូចនេះខ្លួនពិនិត្យឃើញថា គ្មានឯកសារណាមួយបញ្ជាក់ថា ដីកាសះជា នេះចូលជាស្ថាពរឡើយ ។

-ហើយចំពោះសាលាឧទ្ធរណ៍បានសម្រេចសេចក្តីមិនប៉ះពាល់ដល់ភាគីណាមួយទេ វាគ្រាន់តែជាវិធានការបណ្តោះអាសន្នតែប៉ុណ្ណោះ ។

សំណូមពរសុំឱ្យក្រុមប្រឹក្សាជំនុំជំរះ សម្រេចតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់តំណាងលោកWu Pi Chi សចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣៤៣ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣ របស់លោកសួរ សារិទ្ធ តំណាងឱ្យលោក Wu Pi chi ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាច លើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា នាពេលសវនាការនេះមេធាវី និងតំណាងឱ្យលោកអាន ដោពឹង ជាតំណាងលោក Wei Bing Qing បានសុំដកបណ្តឹងសាទុក្ខរបស់ខ្លួន តុលាការកំពូលគប្បីអនុញ្ញាត តាមកាសុំ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចផ្អាកការអនុវត្តដីកាសម្រេចតាមលទ្ធផលសះជាលេខ០១(ជ) ចុះថ្ងៃទី០៨-៤-២០០៣ របស់តុលាការក្រុងភ្នំពេញ និងបង្កើតគណៈកម្មការពិសេសមួយ ដើម្បីធ្វើការលក់ដូរ ជួលតូបស្តង់ និងអាគារផ្សេងៗ រួចយកប្រាក់ទៅតម្កល់ទុកនៅ តុលាការក្រុងភ្នំពេញ ដោយអាងហេតុថា អ្នកស្រី Xe Xiang Rong មានភាគហ៊ុននៅក្នុង ក្រុមហ៊ុនហ៊ុយសេង ហើយលោក Wei Bing Qing បានធ្វើការសះជា ជាមួយក្រុមហ៊ុន GCD (តៃវ៉ាន់) ដោយពុំមានការឯកភាពពីសមាជិកភាគហ៊ុននោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា :

លោក Wei Bing Qing និងអ្នកស្រីស៊ា ស៊ាងរ៉ុង សុទ្ធតែជាម្ចាស់ភាគហ៊ុននៃក្រុមហ៊ុន ហ៊ុយសេង ហើយកន្លងមកអ្នកស្រីស៊ា ស៊ាងរ៉ុង បានប្រគល់សិទ្ធិជូនលោក Wei Bing Qing ឱ្យជំនួសអ្នកស្រីនៅមុខតុលាការ ដើម្បីធ្វើការសន្យា ឬធ្វើការបញ្ជាក់ផ្សេងៗជូនតុលាការរួចហើយ ហើយពុំមានលិខិតណាលុបបំបាត់នូវលិខិតប្រគល់សិទ្ធិចុះថ្ងៃទី១៨-០១-២០០២ នេះទេ ។ ដូច្នេះ អ្នកស្រីស៊ា ស៊ាងរ៉ុង ពុំមានគុណសម្បត្តិដើម្បីតាំងខ្លួនជាតតិយជនប្តឹងជំទាស់នឹងការអនុវត្តដីកាសម្រេចតាមលទ្ធផលសះជាលេខ០១(ជ)ចុះថ្ងៃទី០៨-៤-២០០៣ របស់តុលាការក្រុងភ្នំពេញបានទេ។

-យល់ឃើញថា ដីកាសម្រេចតាមលទ្ធផលសះជារបស់តុលាការក្រុងភ្នំពេញធ្វើឡើងដោយ ផ្អែកលើកំណត់ហេតុផ្សះផ្សាសំរុះសំរួលនៅមុខចៅក្រម ដែលមានមេធាវីមានគូភាគី ចូលរួមដែរ ដូច្នេះពុំអាចចាត់ទុកបានថា ការផ្សះផ្សានេះធ្វើឡើងដោយមានការកៀបសង្កត់ និងគំរាមកំហែង ទេ ។ ម្យ៉ាងទៀតលោកអាន ដោពីង ជាតំណាងលោកWei Bing Qing បានដាក់ពាក្យប្តឹងបដិសេធដីកាសម្រេចតាមពាក្យសុំលេខ១១(ញ) ចុះថ្ងៃទី១០-៦-២០០៣ ដែលបានសម្រេចផ្អាកការ អនុវត្តដីកាសម្រេចតាមលទ្ធផលសជា ទៀតផង ។

-យល់ឃើញថា តាមសារាចរលេខ០៤ សរច ចុះថ្ងៃទី ០៨-៩-១៩៨៤ របស់ក្រសួងយុត្តិធម៌ និងតាមគោលការណ៍ជាយុត្តិសាស្ត្ររបស់តុលាការដីកាសម្រេចតាមលទ្ធផលសះជាមានអានុភាពអនុវត្តដូចជាសាលក្រមស្ថាពរដែរ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចសេចក្តីឱ្យផ្អាកការអនុវត្តដីកាសម្រេចតាម លទ្ធផលសះជាដោយអាងហេតុថា ដើម្បីការពារផលប្រយោជន៍របស់គូភាគីផងនិងដើម្បីងាយស្រួល អនុវត្តពេលដែលរឿងអង្គសេចក្តីចប់ជាស្ថាពរនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះរឿងកិច្ចការប្រញាប់នេះ គឺជារឿងទាក់ទងនឹងការអនុវត្តដីកាសម្រេចតាមលទ្ធផលសះជា ដែលមានអានុភាពដូចសាលក្រមដែរ ។ ដូច្នេះតាមគោលការណ៍មាត្រា៦៦ នៃច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី បើបណ្តឹងទាស់គ្មានមូលហេតុច្បាស់លាស់ទេ តុលាការត្រូវតែបដិសេធ និងបន្តអនុវត្តសាលក្រមត ទៅទៀតបាន ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចបង្កើតគណៈកម្មការលក់ ដួល តូបស្តង់ និងអាគារផ្សេងៗ ព្រមទាំងគ្រប់គ្រងថវិកា និងចាយវាយនោះ គឺជាការសម្រេចដោយពុំមានពាក្យ បណ្តឹងសុំរបស់គូភាគីនៅតុលាការជាន់ទី១ ទេ ។

-យល់ឃើញថា គូភាគីពុំបានមកចូលរួមនាសវនាការនេះទេ ប៉ុន្តែមានមេធាវីមកចូលរួម គ្រប់ចំនួនហើយ ដូច្នេះតុលាការកំពូល ជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១២៥ (ឈ) ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិ ច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីកំបាំងមុខគូក្តី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ៣៤៣ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣ របស់លោកសួរ សារិទ្ធ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-អនុញ្ញាតឱ្យលោកមេធាវីតំណាងឱ្យលោកអាន ដោពីង ជាតំណាងលោកWei Bing Qing ដកបណ្តឹងសាទុក្ខតាមសុំ

៣-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ១២៩(ឈ) ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូលដោយឥតបង្វិល ។

៤-សម្រេចអោយអនុវត្តដីកាសម្រេចតាមលទ្ធផលសះជាលេខ០១(ជ) ចុះថ្ងៃទី០៨-៤-២០០៣ របស់តុលាការក្រុងភ្នំពេញ បន្តទៀត ។

៥-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ៤៥១ប្រ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់តុលាការកំពូលទៅបញ្ចូលក្នុងរឿងអង្គសេចក្តីនៅតុលាការក្រុងភ្នំពេញ។

៦-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៣៨.០០០រ ដែលចុងចម្លើយពីរនាក់បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ជាវង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ នៅសល់១៩.០០០៛ បង្វិលឱ្យលោក សួរ សារិទ្ធ និងលោកអាន ដោពីង ម្នាក់ពាក់កណ្តាល ហើយ តម្រូវឱ្យដើមចោទសងប្រាក់១៩.០០០៛ ទៅចុងចម្លើយទាំងពីរនាក់វិញ ។

៧-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៤ ។